ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ
លេខ ៖ ៤៧៧/២១ សរណន

# សេចក្តីណែនាំ
## ស្តីពី
## ការផ្អាកជាបណ្តោះអាសន្នការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ និងការផ្អាកការជួបជុំរយៈពេល១៤ថ្ងៃ ចាប់ពីថ្ងៃទី១៥ ដល់២៨ ខែមេសា ឆ្នាំ២០២១ ក្នុងភូមិសាស្ត្រខេត្តកំពង់ធំ

ស្ថិតក្នុងស្ថានភាពដែលការរីករាលនៃជំងឺកូវីដ១៩ មិនទាន់ធូរស្រាលនៅឡើយ និងដើម្បីធានាសុខភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ និងជាពិសេសក្នុងគោលបំណងកាត់ផ្តាច់នូវការរីករាលដាលនៃជំងឺកូវីដ១៩កាន់តែខ្លាំងចូលក្នុងសហគមន៍ រដ្ឋបាលខេត្តសូមណែនាំឲ្យអនុវត្តវិធានការមួយចំនួន ចាប់ពីថ្ងៃទី **១៥ ដល់២៨ ខែមេសា ឆ្នាំ២០២១** ដូចខាងក្រោម៖

១. ត្រូវផ្អាកជាបណ្តោះអាសន្នការលក់គ្រឿងស្រវឹងគ្រប់ប្រភេទ នៅតាមផ្សារ ម៉ាត ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ អាជីវកម្មផ្នែកអាហារ-ភេសជ្ជៈ និងដេប៉ូចែកចាយគ្រឿងស្រវឹងទាំងអស់

២. ត្រូវផ្អាកជាបណ្តោះអាសន្នការប្រមូលផ្តុំគ្នាទទួលទានគ្រឿងស្រវឹង ឬជួបជុំគ្នាកំសាន្តនៅគ្រប់ទីកន្លែង

៣. ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត មន្ទីរទេសចរណ៍ មន្ទីរពាណិជ្ជកម្ម និងរដ្ឋបាលក្រុង/ស្រុក ត្រូវចុះណែនាំ និងត្រួតពិនិត្យតាមគោលដៅខាងលើ ឲ្យបានហ្មត់ចត់បំផុត

៤. គ្រប់ផ្សារ ម៉ាត ភោជនីយដ្ឋាន អាហារដ្ឋាន តូបអាហារ ហាងកាហ្វេ ហាងភេសជ្ជៈ អាជីវករលក់ដូរគ្រឿងស្រវឹងគ្រប់ប្រភេទ និងបុគ្គលដែលមិនអនុវត្តតាមការណែនាំខាងលើ ត្រូវអនុវត្តវិធានការរដ្ឋបាល និងវិធានច្បាប់ដោយគ្មានការលើកលែងឡើយ។

ទទួលបានសេចក្តីណែនាំនេះ ស្នងការដ្ឋាននគរបាលខេត្ត បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត មន្ទីរទេសចរណ៍ មន្ទីរពាណិជ្ជកម្ម រដ្ឋបាលក្រុង/ស្រុក និងមន្ទីរ/អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តឲ្យមាន ប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ០៤កើត ខែពិសាខ ឆ្នាំឆ្លូវ ព.ស.២៥៦៤
ខេត្តកំពង់ធំ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១
អភិបាល

សុខ លូ

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ក្រសួងសុខាភិបាល
- ក្រុមប្រឹក្សាខេត្ត
  "ដើម្បីគោរពជូនជ្រាប"
- មន្ទីរ/អង្គភាពជុំវិញខេត្ត
- រដ្ឋបាលក្រុង/ស្រុក
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ